EMBASSY OF JAPAN
IN CAMBODIA

PRESS RELEASE

No. 29PR-26/EoJ 18 November 2026

Japan Provides Assistance For Construction of a Vocational Training Building and Installation of Training Equipment for National Vocation Institute of Battambang

The Government of Japan will provide US$204,101 for the National Vocation Institute of Battambang under the framework of *the Grant Assistance for Grassroots Projects ("KUSANONE")*. The Grant Contract was signed today between H.E. Mr. ISHIZUKI Hideo, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representative of the National Vocation Institute of Battambang to carry out the following project.

Project Title: 'The Project for the Construction of Vocational Training Building and the Installation of Equipment at National Vocation Institute of Battambang'
Grant: US$204,101
Recipient: National Vocation Institute of Battambang

The grant will be utilized to fund the construction of a vocational training building, including four classrooms, and the installation of 49 vocational training equipment items for the Food Processing and Analysis Department at the National Vocation Institute of Battambang. These facilities and equipment will enable the students to acquire practical skills required for employment, while also contributing to the reintegration of returning migrant workers into Cambodian society following the border conflict and supporting the development of a skilled workforce in the region.

Japan's "KUSANONE" Projects commenced in Cambodia in 1991 to support Cambodia's reconstruction and development at the grassroots level. The assistance aims to safeguard vulnerable individuals affected by factors such as poverty and/or misfortunes that directly threaten their lives, livelihood and dignity, while also fostering self-reliance within local communities. Since 1991, the Government of Japan has provided over US$73 million for mainly local authorities and non-governmental organizations to implement over 700 KUSANONE projects across Cambodia.

Embassy of Japan in Cambodia
Tel: 023-217-161
Email: eco.jpn@pp.mofa.go.jp, Website: http://www.kh.emb-japan.go.jp

ស្ថានទូតជប៉ុន

ប្រចាំកម្ពុជា

សេចក្តីប្រកាសព័ត៌មាន

លេខ. 29PR-26/EoJ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៦

ជប៉ុនផ្តល់ជំនួយ
សម្រាប់ការសាងសង់អគារបណ្ណុះបណ្តាលវិជ្ជាជីវៈ និងការតម្លើងឧបករណ៍
នៅវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាចំនួន ២០៤,១០១ ដុល្លារអាមេរិក ដល់វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងថ្នាក់មូលដ្ឋាន (គូសាណូណិ)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ ឯកឧត្តម អ៊ីស៊ីហ៊្សុគិ ហ៊ីដេអុ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង អ្នកតំណាងវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង ដើម្បីអនុវត្តគម្រោងខាងក្រោម៖

ឈ្មោះគម្រោង៖ គម្រោងសាងសង់អគារបណ្ណុះបណ្តាលវិជ្ជាជីវៈ និងការតម្លើងឧបករណ៍ នៅវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង
ថវិកាជំនួយចំនួន៖ ២០៤,១០១ ដុល្លារអាមេរិក
ស្ថាប័នទទួលជំនួយ៖ វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង

ថវិកាជំនួយនេះ នឹងត្រូវបានប្រើប្រាស់ដើម្បីសាងសង់អគារបណ្ណុះបណ្តាលវិជ្ជាជីវៈ ដែលរួមមានបន្ទប់រៀន ចំនួន៤ និងការតម្លើងឧបករណ៍បណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន៤៩ មុខ សម្រាប់ដេប៉ាតឺម៉ង់កែច្នៃ និងវិភាគចំណីអាហារ នៅវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង។ បរិក្ខារ និងឧបករណ៍ទាំងនេះ នឹងជួយឱ្យសិស្សទទួលបានជំនាញជាក់ស្តែង ដែលចាំបាច់ក្នុងការងារ ព្រមទាំងរួមចំណែកក្នុងការធ្វើសមាហរណកម្ម ពលករចំណាកស្រុកដែលត្រឡប់មកវិញ ឱ្យចូលទៅក្នុងសង្គមកម្ពុជា បន្ទាប់ពីជម្លោះព្រំដែន និងគាំទ្រដល់ការអភិវឌ្ឍកម្លាំងពលកម្មជំនាញនៅក្នុងតំបន់។

គម្រោងគូសាណូណិរបស់ជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តារបនាប្រទេសឡើងវិញ នៅតាមកម្រិតមូលដ្ឋាន។ ជំនួយឥតសំណងនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង/ឬ ភាពអកុសលនានា ដែលអាចគំរាមកំហែងដោយផ្ទាល់

ដល់អាយុជីវិត ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៧៣លាន ដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគួសាណាណិ ជាង៧០០គម្រោង នៅទូទាំងប្រទេសកម្ពុជា៕

ស្ថានទូតជប៉ុនប្រចាំកម្ពុជា

ទូរសព្ទ៍ៈ ០២៣-២១៧-១៦១

អ៊ីម៉ែលៈ eco.jpn@pp.mofa.go.jp គេហទំព័រៈ http://www.kh.emb-japan.go.jp

សុន្ទរកថារបស់ ឯកឧត្តម អ៊ីស៊ីហ៊ីរ៉ូគិ ហ៊ីដេអុ
ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងថ្នាក់មូលដ្ឋាន
ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៦

អរុណសួស្តី និងសូមស្វាគមន៍មកកាន់ស្ថានទូតជប៉ុន។

ជាដំបូង ខ្ញុំសូមស្វាគមន៍នូវវត្តមាន

- **ឯកឧត្តម ថង សាម៉ុន** អគ្គនាយករងនៃអគ្គនាយកដ្ឋាន អប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- **លោក ហេង ងួនហ៊ាត** នាយកវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង
- លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី។

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានរៀបចំពិធីចុះហត្ថលេខាថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយឥតសំណង ដែលត្រូវបានអនុវត្តក្រោម គ្រោងការណ៍ជំនួយឥតសំណងគូសាណូណាសម្រាប់គម្រោងថ្នាក់មូលដ្ឋាន។

ខ្ញុំសូមថ្លែងអំណរគុណ ឯកឧត្តម ថង សាម៉ុន លោក ហេង ងួនហ៊ាត និងភ្ញៀវកិត្តិយសទាំងអស់ សម្រាប់វត្តមានអញ្ជើញចូលរួមនាថ្ងៃនេះ។

ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយឥតសំណងគូសាណូណានៅកម្ពុជា ដើម្បីជួយដោយផ្ទាល់ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលនានា ក្នុងការអនុវត្តគម្រោងរបស់ពួកគាត់។ ក្នុងភាសាជប៉ុន គូសាណូណា មានន័យថា "ឫសស្មៅ"។ នៅក្នុងរយៈពេលជាង ៣៥ឆ្នាំកន្លងមកនេះ ស្ថានទូតជប៉ុន បានអនុវត្តជាង ៧០០គម្រោង នៅទូទាំងប្រទេសកម្ពុជា តាមរយៈគ្រោងការណ៍ជំនួយឥតសំណងនេះ។ ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលគម្រោងទាំងនេះបន្តបង្កើតការផ្លាស់ប្តូរជាក់ស្តែង ក្នុងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនកម្ពុជានៅថ្នាក់មូលដ្ឋាន។

ខ្ញុំសង្ឃឹមថា គម្រោងនេះនឹងចូលរួមចំណែកកែលម្អបរិយាកាសបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងខេត្តបាត់ដំបង និងតំបន់ជុំវិញ ដោយផ្តល់ឱកាសកាន់តែច្រើនដល់យុវជន និងពលករចំណាកស្រុកដែលវិលត្រឡប់មកវិញ ក្នុងការទទួលបានជំនាញជាក់ស្តែង ពង្រីកឱកាសការងារ និងជួយសម្រួលដល់ការធ្វើសមាហរកម្ម ពួកគេឱ្យចូលទៅក្នុងសង្គមកម្ពុជាវិញ។ តាមរយៈគម្រោងនេះ ខ្ញុំសង្ឃឹមថាធនធានមនុស្សដែលមានជំនាញក្នុងវិស័យកែច្នៃចំណីអាហារនឹងត្រូវបានអភិវឌ្ឍ ដែលនឹងជួយជំរុញដល់ការធ្វើពិពិធកម្មឧស្សាហកម្ម និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា។

លើសពីនេះទៅទៀត ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គម្រោងនេះនឹងជួយជំរុញកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធជាមួយក្រុមហ៊ុនជប៉ុន តាមរយៈការផ្តល់ឱកាសហាត់ការ និងការផ្លាស់ប្តូរធនធានមនុស្សដែលមានជំនាញ ដែលនឹងជួយពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងសេដ្ឋកិច្ច និងមិត្តភាពដ៏យូរអង្វែងរវាងប្រទេសជប៉ុន និងកម្ពុជា។

ដោយបានមកដល់ប្រទេសកម្ពុជាកាលពីពីរខែមុន ខ្ញុំមានឱកាសបានទៅទស្សនកិច្ចខេត្តមួយចំនួនក្នុងនោះមានខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់។ តាមរយៈដំណើរទស្សនកិច្ចទាំងនេះ ខ្ញុំបានសង្កេតមើលការអភិវឌ្ឍរបស់ប្រទេសកម្ពុជា និងជាមួយគ្នាដែរ ខ្ញុំបានឃើញថា នៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយទៅមុខទៀត ដើម្បីកែលម្អគុណភាពជីវិតរបស់ប្រជាជន។ ជប៉ុន នឹងបន្តចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ តាមរយៈគ្រោងការណ៍ជំនួយអភិវឌ្ឍន៍ផ្លូវការផ្សេងៗ រួមទាំង "គូសាណូណា" ផងដែរ។

ជាចុងក្រោយ ខ្ញុំសូមជូនពរ លោក លោកស្រី ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ សុភមង្គល និងសូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន និងស៊ីជម្រៅ។

សូមអរគុណច្រើនសម្រាប់ការយកចិត្តទុកដាក់ស្តាប់។